# សេចក្តីថ្លែងការណ៍រួម

# អង្គការសង្គមស៊ីវិលសូមអំពាវនាវឱ្យទម្លាក់ចោលសេចក្តីព្រាង *ច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ*

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០

**យើងខ្ញុំជាអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ និងសហគមន៍ដែលមានរាយនាមដូចខាងក្រោម សូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ទម្លាក់ចោលនូវសេចក្តីព្រាង*ច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ* ដែលមានលក្ខណៈគាបសង្កត់ និងសូមឱ្យគោរពទៅតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។** សេចក្តីព្រាងច្បាប់នេះមានបទប្បញ្ញត្តិជាច្រើនដែលមានវិសាលភាពទូលំទូលាយក្នុងការកំណត់បទល្មើសចំពោះសកម្មភាពស្របច្បាប់ប្រចាំថ្ងៃជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ហើយដែលនឹងរំលោភលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ខាងសមាគម ខាងការជួបប្រជុំនិងសិទ្ធិមនុស្សផ្សេងៗទៀត។ ប្រសិនបើសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័ត ច្បាប់នេះនឹងក្លាយជាច្បាប់ដែលមានលក្ខណៈគាបសង្កត់មួយផ្សេងទៀតនៅក្នុងក្របខ័ណ្ឌច្បាប់ដែលប៉ះពាល់សិទ្ធិមនុស្សធ្ងន់ធ្ងរ។

សេចក្តីព្រាងច្បាប់នេះត្រូវបានតាក់តែងឡើងក្នុងគោលបំណងបញ្ញត្តអំពីការប្រើប្រាស់ទីកន្លែងសាធារណៈ និងការបង្ហាញឥរិយាបទជាសាធារណៈនៅទីកន្លែងសាធារណៈទាំងនោះ។ សេចក្តីព្រាងច្បាប់នេះចែងអំពីសោភ័ណភាព អនាម័យ បរិស្ថាន ភាពស្ងប់ស្ងាត់ និងតម្លៃសង្គម ដែលទាំងអស់នេះស្ថិតក្នុងគោលបំណងទូលំទូលាយក្នុងការរក្សា "*សណ្តាប់ធ្នាប់សាធារណៈ*"។ សេចក្តីព្រាងច្បាប់នេះព្យាយាមកំណត់ការហាមឃាត់នូវសកម្មភាពជាក់លាក់មួយចំនួនដែលរៀបរាប់អំពីប្រភេទនៃការកំណត់ទោសទណ្ឌផ្សេងៗប្រសិនបើមិនគោរពតាម និងផ្តល់អំណាចដល់អាជ្ញាធរកម្ពុជានៅគ្រប់លំដាប់ថ្នាក់ដើម្បីអនុវត្តដោយពុំផ្អែកលើមូលដ្ឋានគតិយុត្តិ ក្រោមហេតុផលធ្វើឱ្យ "*សង្គមកាន់តែមានភាពស៊ីវិល័យ*"។ យើងខ្ញុំមានក្តីបារម្ភយ៉ាងខ្លាំងចំពោះបទប្បញ្ញត្តិដែលមានអត្ថន័យទូលំទូលាយ និងមានលក្ខណៈបំពានជាច្រើនក្នុងសេចក្តីព្រាងច្បាប់នេះ ដែលរំលោភលើកិច្ចការពារសិទ្ធិមនុស្សជាច្រើនដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា("រដ្ឋធម្មនុញ្ញ") និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នក្នុងនោះរួមទាំង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* ("ក.អ.ស.ព.ន") និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.អ.ស.ស.ស.វ)។ យើងខ្ញុំសូមគូសបញ្ជាក់នូវក្តីបារម្ភចម្បងៗដូចខាងក្រោម។ ទោះជាយ៉ាងនេះក្តី ការទម្លាក់ចោលទាំងស្រុងនូវសេចក្តីព្រាងច្បាប់ដែលពុំចាំបាច់នេះគឺជាការប្រសើរ។

១. ***វិសាលភាពនិងគោលបំណង៖*** សេចក្តីព្រាងច្បាប់នេះមានវិសាលភាពទូលំទូលាយ ហើយការបញ្ចូលបញ្ញត្តិហាមឃាត់ដែលមានន័យទូលំទូលាយលើសកម្មភាពមួយចំនួននោះ ស្ទើរតែពុំអាចអនុវត្តបានជាទូទៅដែលផ្ទុយទៅនឹងគោលការណ៍នីតិរដ្ឋជាសកលដែលមានជាយូរមកហើយ។ មាត្រា ១ នៃសេចក្តីព្រាងច្បាប់នេះចែងអំពីគោលបំណង «*ធានាដល់ការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ ឱ្យមានរបៀបរៀបរយ សោភ័ណភាព អនាម័យ បរិស្ថាន ភាពស្ងប់ស្ងាត់ សុវត្ថិភាពសង្គម រក្សាប្រពៃណីជាតិនិងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ*»។ វាក្យសព្ទនិងនិយមន័យជាច្រើននៅពុំទាន់ត្រូវបានពន្យល់ឱ្យបានច្បាស់លាស់ និងដោយអាស្រ័យថាដើម្បីតម្លៃសង្គម ដែលអាចបកស្រាយផ្សេងៗគ្នា គ្មានមូលដ្ឋានគតិយុត្តិ និងអាចផ្លាស់ប្តូរជាបន្តបន្ទាប់។ កង្វះភាពច្បាស់លាស់នេះជាបច្ច័យមួយនាំឱ្យមានការបកស្រាយផ្សេងៗក្នុងការអនុវត្តច្បាប់នេះ ដែលធ្វើឱ្យសាធារណជនពិបាកយល់ឱ្យបានច្បាស់លាស់ ដោយពុំដឹងជាមុនថាតើសកម្មភាពណាខ្លះដែលផ្ទុយឬស្របនឹងច្បាប់នេះ។ ទោះបីជាសណ្តាប់ធ្នាប់សាធារណៈគឺជាគោលបំណងស្របតាមផ្លូវច្បាប់ដែលត្រូវបានអនុញ្ញាតក្រោម ក.អ.ស.ព.ន និង ក.អ.ស.ស.ស.វ ក៏ដោយក្តី ប៉ុន្តែអត្ថន័យនៃពាក្យសណ្តាប់ធ្នាប់សាធារណៈនេះអាចត្រូវបានគេលើកយកជាសម្អាងដើម្បីរឹតត្បិតសិទ្ធិមនុស្សក្នុងស្ថានភាពចង្អៀតណាមួយ។ ការរឹតត្បិតណាមួយក្រោមហេតុផលសណ្តាប់ធ្នាប់សាធារណៈ អាចធ្វើឡើងតែក្នុងករណីចាំបាច់ សមាមាត្រនិងជាជម្រើសចុងក្រោយតែប៉ុណ្ណោះ។

២. ***ការរើសអើង៖*** សេចក្តីព្រាងច្បាប់នេះប៉ះពាល់យ៉ាងខ្លាំងលើក្រុមបុគ្គលដែលងាយរងគ្រោះ ដែលផ្ទុយទៅនឹងការធានាអំពីការមិនរើសអើងដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ក.អ.ស.ព.ន ក.អ.ស.ស.ស.វ និងលិខិតូបករណ៍សិទ្ធិមនុស្សដែលត្រូវអនុវត្តដទៃទៀត។ សេចក្តីព្រាងច្បាប់នេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើប្រជាពលរដ្ឋដែលមានភាពលំបាកផ្នែកសេដ្ឋកិច្ចនិងអ្នកធ្វើការងារក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលភាគច្រើននៃអ្នកទាំងនោះពឹងផ្អែកលើសកម្មភាពនានាដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ដែលចំណុចនេះត្រូវបានហាមឃាត់នៅក្នុងសេចក្តីព្រាងច្បាប់នេះ ។ ឧទាហរណ៍ មាត្រា ១១ ហាមឃាត់ "ការតាំង ឬការលក់ដូរទំនិញបំពានលើទីសាធារណៈគ្មានសណ្តាប់ធ្នាប់" ដែលជាប្រភពចំណូលមួយផ្នែកនៅប្រទេសកម្ពុជា ចំណែកមាត្រា៣៧ (ឈ) ហាមឃាត់ "ការសុំទានតាមគ្រប់រូបភាព"។ មាត្រា ១១ ហាមឃាត់ការយកទីសាធារណៈជា "ទីស្នាក់អាស្រ័យនៅបណ្តោះអាសន្ន" ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ បុគ្គលគ្រប់រូបមានសិទ្ធិរស់នៅក្នុងជីវភាពសមរម្យហើយប្រទេសកម្ពុជានៅកំពុងប្រឈមកង្វះប្រព័ន្ធកិច្ចគាំពារសង្គមដែលអាចធានាសិទ្ធិនេះដល់ប្រជាពលរដ្ឋដែលប្រឈមហានិភ័យក្នុងសង្គមនៅឡើយ។ បន្ថែមលើកង្វះការគាំទ្រដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះនេះ សេចក្តីព្រាងច្បាប់នេះមានឥទ្ធិពលកាន់តែធ្វើឱ្យមានភាពក្រីក្រនិងវិសមភាពសេដ្ឋកិច្ចកើនឡើងថែមទៀត។

សេចក្តីព្រាងច្បាប់នេះមានបទប្បញ្ញត្តិមួយចំនួន ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់បុគ្គលដែលមានបញ្ហាសុខភាពផ្លូវចិត្ត ព្រមទាំងជាបច្ច័យឱ្យមានការរើសអើងនិងការប្រមាថមាក់ងាយផងដែរ។ សេចក្តីព្រាងច្បាប់នេះបញ្ញត្តអំពីការរឹតត្បិតតាមអំពើចិត្តនិងគ្មានមូលដ្ឋានច្បាស់លាស់លើបុគ្គល "*វិបល្លាសស្មារតី*" ដែលពន្យល់អត្ថន័យមិនច្បាស់លាស់ថា "*សំដៅដល់ការប្រែប្រួលស្មារតីដែលនាំឱ្យបាត់បង់ការដឹងខុសត្រូវ*" ។ និយមន័យនេះខ្វះមូលដ្ឋានផ្លូវច្បាប់និងវិទ្យាសាស្ត្រ និងពុំមានតម្រូវឱ្យធ្វើរោគវិនិច្ឆ័យពីអ្នកជំនាញដែលប្រការនេះហាក់ដូចជាសន្មតលើស្ថានភាពសុខភាពផ្លូវចិត្តរបស់បុគ្គលទាក់ទងនឹងលទ្ធភាពនៃការវិនិច្ឆ័យដឹងខុសត្រូវ ហើយដោយមិនថ្លឹងថ្លែងដល់ស្ថានភាពធ្ងន់ធ្ងរនៃជំងឺ "*វិបល្លាសស្មារតី*" ផងនោះ។ ហេតុដូច្នោះច្បាប់នេះពុំស្របជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ព្រោះពុំបានកំណត់ថាតើអាការៈជំងឺបែបណាដែលអាចរាប់ថាជាប្រភេទជំងឺ "*វិបល្លាសស្មារតី*" ដោយអនុលោមតាមស្តង់ដារវេជ្ជសាស្ត្រដែលមានការទទួលស្គាល់ជាអន្តរជាតិនោះឡើយ។ សេចក្តីព្រាងច្បាប់នេះ ហាមឃាត់បុគ្គលទាំងនេះពី "*ការដើររហេត រហូតតាមទីសាធារណៈ*"(មាត្រា២៥)។ ការរឹតត្បិតទៅលើការធ្វើដំណើរចំពោះក្រុមបុគ្គលនេះ ដោយពុំតម្រូវឱ្យមានការកំណត់ថាតើការរឹតត្បិតនោះធ្វើឡើងក្នុងករណីចាំបាច់ ផ្អែកតាមស្ថានភាពបុគ្គលជាក់ស្តែងឬយ៉ាងណានោះនឹងបង្កផលប៉ះពាល់ដល់សិទ្ធិសេរីភាពនៃការធ្វើដំណើរដែលធានាក្នុងនៅមាត្រា៩នៃក.អ.ស.ព.ន និង រំលោភសិទ្ធិដែលត្រូវការពារក្រោមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនៃជនមានពិការភាព ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ សេចក្តីព្រាងច្បាប់នេះនឹងបង្កក្តីបារម្ភជាខ្លាំង ពីព្រោះនឹងរារាំងប្រជាពលរដ្ឋដែលមានបញ្ហាសុខភាពផ្លូវចិត្តក្នុងការទទួលបានសេរីភាពមូលដ្ឋានរបស់ខ្លួន ព្រមទាំងអនុញ្ញាតឱ្យមានការរើសអើងដោយផ្អែកលើពិការភាពដោយពុំសមហេតុផល។

បន្ថែមលើក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះខាងលើ សេចក្តីព្រាងច្បាប់ដែលមានបទប្បញ្ញត្តិគួរឱ្យព្រួយបារម្ភនេះ អាចនាំឱ្យមានការរើសអើងលើស្ត្រីកាន់តែខ្លាំងថែមទៀត(មាត្រា៣៧ ដូចការវិភាគខាងក្រោម)។

៣. ***សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម៖*** សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈបង្កក្តីបារម្ភយ៉ាងខ្លាំងចំពោះការអនុវត្តសេរីភាពខាងការជួបប្រជុំនិងសេរីភាពចងក្រងសមាគមនៅកម្ពុជា។ មាត្រា៦ និង មាត្រា៣០ តម្រូវឱ្យមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ទើបអាច"*ប្រើប្រាស់ទីសាធារណៈ*" បាន និងអនុញ្ញាតឱ្យអាជ្ញាធរបញ្ឈប់ព្រឹត្តិការណ៍ ប្រសិនបើពុំមានការអនុញ្ញាតពីសំណាក់អាជ្ញាធរ។ ស្របគ្នាជាមួយមាត្រា៤៨ ដែលទុកជានិរាករណ៍នូវបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីព្រាងច្បាប់នេះ កែប្រែនូវគោលការណ៍ជូនដំណឹងជាមុនដែលមានចែងក្នុងមាត្រា៥ និងមាត្រា៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដោយដាក់ជំនួសវិញនូវការតម្រូវឱ្យស្នើសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុន ដែលផ្ទុយទាំងស្រុងជាមួយច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងនោះរួម

ទាំងមាត្រា២១ នៃ ក.អ.ស.ព.ន។ បទប្បញ្ញត្តិទាំងនេះ ផ្តល់មូលដ្ឋានសម្រាប់ធ្វើការជ្រៀតជ្រែកតាមអំពើចិត្ត ដែលបុគ្គលនិងសមាគមជាច្រើនបានជួបប្រទះរួចហើយនៅពេលរៀបចំព្រឹត្តិការណ៍នានា។ ម្យ៉ាងវិញទៀត មាត្រា៣១ នៃសេចក្តីព្រាងច្បាប់នេះអនុញ្ញាតឱ្យអាជ្ញាធរអាចបដិសេធ ឬបញ្ឈប់ព្រឹត្តិការណ៍នានាដោយផ្អែកលើមូលហេតុដែលមានអត្ថន័យទូលំទូលាយ ៦ យ៉ាងនេះ ក្នុងនោះមានដូចជា ប្រសិនបើព្រឹត្តិការណ៍នោះបង្ក"*ការប្រេទូសរាយជាមួយកងកម្លាំងសមត្ថកិច្ច*" ឬ "*បង្កការប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ*" ជាដើមដែលចំណុចនេះមានន័យទូលំទូលាយខ្លាំង និងអាចត្រូវបានប្រើប្រាស់ដើម្បីហាមឃាត់ការជួបប្រជុំ ឬព្រឹត្តិការណ៍នានាតាមឆន្ទានុសិទ្ធិដែលអាជ្ញាធរមានសមត្ថកិច្ចជាអ្នកកំណត់ដោយពុំមានការព្យាករណ៍ពីលទ្ធភាពអាចធ្វើទៅបាន ឬភាពច្បាស់លាស់ក្នុងការអនុវត្តនិងពុំមានការថ្លឹងថ្លែងឱ្យបានត្រឹមត្រូវដល់ការអនុវត្តសេរីភាពមូលដ្ឋាន។ ម្យ៉ាងទៀត មាត្រា ៣៣ កំណត់លើបរិមាណនៃចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ជួបប្រជុំមិនឱ្យលើសពីចំនួន "២ (ពីរ) នាក់ ក្នុង១,២ ម៉ែត្រក្រឡា"។ បញ្ញត្តិដែលមានលក្ខណៈបំពាននេះ ផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការរឹតត្បិតដោយស្របច្បាប់លើសកម្មភាពនៃការជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម តាមរយៈការកំណត់នូវចំនួនអ្នកចូលរួមដោយពុំតម្រូវឱ្យអាជ្ញាធរវាយតម្លៃឱ្យបានច្បាស់ថា ការកម្រិតនោះចាំបាច់ក្នុងកាលៈទេសៈជាក់លាក់ណាមួយដែរឬយ៉ាងណា។ សហគមន៍ជនជាតិដើមភាគតិច អង្គការនៅថ្នាក់មូលដ្ឋាន សហជីព និងសកម្មជននៅថ្នាក់មូលដ្ឋានពឹងផ្អែកលើលទ្ធភាពនេះក្នុងការជួបប្រជុំដើម្បីតស៊ូមតិសម្រាប់សិទ្ធិរបស់ខ្លួន នឹងប៉ះពាល់ធ្ងន់ធ្ងរតាមរយៈបទប្បញ្ញត្តិដែលរឹតត្បិតទាំងនេះ។ តាមរយៈសេចក្តីពន្យល់ទូទៅលេខ៣៧ ថ្មីរបស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិថ្លែងបញ្ជាក់ថា រដ្ឋនានាមិនអាចផ្អែកលើនិយមន័យដែលមានខ្លឹមសារមិនច្បាស់លាស់នៃសណ្តាប់ធ្នាប់សាធារណៈ ដើម្បីផ្តល់យុត្តិកម្មលើការរឹតត្បិតដូចដែលសេចក្តីព្រាងច្បាប់នេះចែងនោះទេ។ គណៈកម្មាធិការសង្កត់ធ្ងន់ថា កុំមានការយល់ច្រឡំរវាងពាក្យ "សណ្តាប់ធ្នាប់សាធារណៈ" និង "ច្បាប់និងរបៀបរៀបរយ" ដោយច្បាប់និងរបៀបរៀបរយតម្រូវឱ្យរដ្ឋរក្សា "ភាពអត់ធ្មត់ខ្លាំង" ចំពោះការរំខានណាមួយដោយសារការជួបប្រជុំដោយសន្តិវិធី។

៤. ***សេរីភាពក្នុងការបញ្ចេញមតិ៖*** សេចក្តីព្រាង*ច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ* អនុញ្ញាតឱ្យមានការរំលោភដោយបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ ទីមួយច្បាប់នេះហាមឃាត់ "*ការប្រើពាក្យសម្តីឮខ្លាំងៗ*" (មាត្រា ១៦) និងកំណត់រាល់សំឡេងបង្កឱ្យឮខ្លាំងរំខានដល់អ្នកជទៃត្រូវបញ្ឈប់ចាប់ពីម៉ោង១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង១៤ (ដប់បួន) រសៀល និងចាប់ពី ម៉ោង២២ (ម្ភៃពីរ) យប់ ដល់ម៉ោង ៥ (ប្រាំ)ព្រឹក លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច (មាត្រា១៧) ដែលពុំស្របតាមលក្ខខណ្ឌតម្រូវនៃភាពចាំបាច់សម្រាប់ការសម្រេចនូវគោលបំណងនៃសណ្តាប់ធ្នាប់សាធារណៈនេះ ជាការ

បំពាន ក.អ.ស.ព.ន ។ ជាងនេះទៀត មាត្រា ៣៦ ដែលហាមឃាត់បុរសស្លៀកតែខោអត់ពាក់អាវ ឬស្លៀកតែខោទ្រនាប់បង្ហាញផ្នែកខ្លះនៃកេរភេទ និងហាមឃាត់ស្ត្រីពីការស្លៀកពាក់ខ្លីខើចលើខើចក្រោម ឬ ស្លៀកពាក់ស្តើងមើលឃើញកេរភេទ" ដែល "ប៉ះពាល់ប្រពៃណីជាតិ និងសេចក្តីថ្លៃថ្នូរ" នោះ ជាការបំពានលើសេរីភាពក្នុងការបញ្ចេញមតិ ប៉ះពាល់ដល់ស្វ័យភាពរបស់បុគ្គលនិងពុំបានពន្យល់ច្បាស់លាស់អំពីនិយមន័យនៃសេចក្តីថ្លៃថ្នូរ ដូច្នេះជាការទុកចន្លោះប្រហោងឱ្យមានការអនុវត្តពុំស្មើភាពគ្នា។ មាត្រា៣៦ ក៏នឹងកាន់តែនាំឱ្យមានការរើសអើងលើស្ត្រីដែលប្រឈមផ្នត់គំនិតយេនឌ័របែបអវិជ្ជមាន និងទស្សនៈឱ្យតម្លៃបុរសជាងដែលបានចាក់ឫសក្នុងប្រពៃណីសង្គមជាយូរមកហើយ។ ស្ត្រីនៅកម្ពុជាប្រឈមនឹងការគំរាមកំហែងនិងការដាក់ពន្ធនាគារដោយសារជម្រើសក្នុងការ[ស្លៀកពាក់]របស់ខ្លួន ដោយមានស្ត្រីម្នាក់ធ្លាប់ត្រូវបាន[ផ្តន្ទាទោស]ទាក់ទងនឹងការស្លៀកពាក់របស់នាងរួចហើយក្នុងឆ្នាំ២០២០។ បន្ថែមលើនេះ លោកនាយករដ្ឋមន្ត្រីបាន[បន្ទោសជាសាធារណៈ]លើការស្លៀកពាក់របស់ស្ត្រីដែលជាការជំរុញឱ្យមានអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងនោះរួមទាំងបទល្មើសបំពានផ្លូវភេទជាដើម។ មាត្រា ៦ នឹងបន្ថែមនូវវប្បធម៌នៃការ "*ស្តីបន្ទោសលើជនរងគ្រោះ*" តាមការកំណត់ជាបទល្មើសលើស្ត្រី រួមទាំងជនរងគ្រោះដោយអំពើហិង្សាផងដែរដោយសារតែជម្រើសនៃការស្លៀកពាក់របស់ខ្លួន។

ជាចុងក្រោយ សេចក្តីព្រាងច្បាប់នេះមានឥទ្ធិពលខ្លាំងក្នុងការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិទាំងនៅលើនិងក្រៅបណ្តាញអ៊ីនធឺណិត។ មាត្រា ៣៧ បញ្ញត្តិអំពីហាមឃាត់មានអត្ថន័យពុំច្បាស់លាស់ និងគ្មានមូលដ្ឋានចំពោះការបញ្ចេញមតិដែលប៉ះពាល់ដល់ "*ប្រពៃណីជាតិ និងសេចក្តីថ្លៃថ្នូរ*" ដោយពុំមានការបកស្រាយលម្អិតអំពីបទដ្ឋាននៃសេចក្តីថ្លៃថ្នូរដែលកំណត់ឱ្យសាធារណជនទទួលខុសត្រូវនោះទេ។ ក្នុងនោះមានដូចជា "*ការដាក់បង្ហាញ ឬចែកចាយនូវសំណេរ ឬរូបភាពឬប្រើពាក្យសម្តីមានខ្លឹមសារជេរប្រមាថតាមបណ្តាញព័ត៌មានសង្គម*" "*ការបញ្ចេញអាកប្បកិរិយាប្រចេងប្រចង់*" និង "*ការចែកចាយ ឬដាក់បង្ហាញនូវសំណេរ សញ្ញាសម្គាល់ ឬរូបភាពដែលតំណាងឱ្យការគំរាមកំហែង*"។ វិសាលភាពនៃច្បាប់នេះគ្របដណ្តប់រហូតដល់លំហប្រព័ន្ធអ៊ីនធឺណិត ដែលបន្ថែមក្តីបារម្ភថែមទៀត ដោយសារជាការគាបសង្កត់ដ៏ទូលំទូលាយលើសេរីភាពក្នុងការបញ្ចេញមតិនៅលើប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។ នៅឆ្នាំ២០២០ នេះមានករណី[ចាប់ខ្លួន]មនុស្សជាច្រើន ដោយសារការបញ្ចេញគំនិតយោបល់នៅលើបណ្តាញអ៊ីនធឺណិត។

***៥-ទោសទណ្ឌនិងការអនុវត្តៈ*** សកម្មភាពដែលត្រូវហាមឃាត់ក្នុងសេចក្តីព្រាងច្បាប់នេះគឺប្រឈមទោសទណ្ឌផ្សេងៗរាប់ទាំង "ការព្រមាន" និងការពិន័យផ្នែករដ្ឋបាល" រហូតដល់ "ការដាក់ពន្ធនាគារ និង/ឬការពិន័យជាប្រាក់"។ តាមសេចក្តីព្រាងច្បាប់នេះបុគ្គលល្មើសអាចប្រឈមនឹងទោសដាក់ពន្ធនាគាររយៈពេល១ថ្ងៃ ដល់ ៦ថ្ងៃ និងពិន័យជាប្រាក់ចន្លោះ ១០០.០០០ រៀល ដល់ ៥០០.០០០ រៀល ។ សេចក្តីព្រាង

ច្បាប់នេះពុំបានបញ្ញត្តអំពីការអនុវត្តទោសទណ្ឌទាំងនេះដែលនាំឱ្យអាជ្ញាធរមានឆន្ទានុសិទ្ធិក្នុងការកំណត់ទោសសមស្របចំពោះសកម្មភាពដែលត្រូវហាមឃាត់នីមួយៗ ដែលជាបច្ច័យអាចនាំឱ្យមានការអនុវត្តពុំត្រឹមត្រូវ កង្វះភាពស្របគ្នាក្នុងការអនុវត្ត និងកង្វះការពិចារណាក្នុងការគោរពនិងអនុវត្តតាមច្បាប់។ ដោយសារច្បាប់នេះមានការកំណត់គោលដោយពុំសមាមាត្រ លើក្រុមប្រជាពលរដ្ឋដែលមានការលំបាកផ្នែកសេដ្ឋកិច្ចនោះ ច្បាប់នេះនឹងកំណត់ការពិន័យជាប្រាក់លើបុគ្គលដែលស្ទើតែគ្មានលទ្ធភាពក្នុងការបង់ពិន័យ។ មូលដ្ឋានសម្អាងដែលអាចដាក់ពន្ធនាគារ មានខ្លឹមសារពុំច្បាស់លាស់ដែលពុំអាចទទួលយកបានគឺជាការរំលោភលើគោលការណ៍និត្យានុកូលភាព។ ផ្អែកលើការវិនិច្ឆ័យតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ការដាក់ពន្ធនាគារគឺពុំមែនជាលក្ខខណ្ឌដែលគួរចាំបាច់ឬជាការឆ្លើយតបសមាមាត្រចំពោះការរំលោភបំពាននៃច្បាប់នេះនោះទេ ដូច្នេះហើយ នេះគឺជាការកំណត់ទោសទណ្ឌដែលពុំសមហេតុផល។

មាត្រា ៦ បង្កក្ដីបារម្ភចំពោះការអនុវត្តសេចក្ដីព្រាងច្បាប់នេះ ព្រោះច្បាប់នេះផ្ដល់សិទ្ធិអំណាចដល់អាជ្ញាធរមូលដ្ឋានក្នុង *"ការរៀបចំមន្ត្រីជាប់កិច្ចសន្យាជួយការងាររៀបចំសណ្ដាប់ធ្នាប់សាធារណៈ"*។ *"កងកម្លាំងសន្តិសុខ"* ឬ "កម្លាំងនគរបាល" ជួលដោយអាជ្ញាធរមូលដ្ឋានមានប្រវត្តិជាយូរមកហើយជុំវិញការប្រើអំពើហិង្សាលើបុគ្គលនានា និងអ្នកការពារសិទ្ធិមនុស្សដែលព្យាយាមអនុវត្តសិទ្ធិរបស់ខ្លួន ហើយកម្រនឹងទទួលខុសត្រូវចំពោះអំពើល្មើសនេះណាស់។ កងកម្លាំងសន្តិសុខជាប់កិច្ចសន្យាទាំងនេះបង្កើតឡើងក្រោមឥទ្ធិពលនយោបាយ គ្មានច្បាប់ គ្មានគណនេយ្យភាព និងគ្មានការបណ្ដុះបណ្ដាល ដូច្នេះហើយពួកគេបង្កការគំរាមកំហែងធ្ងន់ធ្ងរដល់ការអនុវត្តសិទ្ធិមនុស្សដោយសន្តិវិធី។

សេចក្ដីព្រាង*ច្បាប់ស្ដីពីសណ្ដាប់ធ្នាប់សាធារណៈ*នេះត្រូវបានបង្កើតឡើងក្នុងពេលកំពុងមានការបង្ក្រាបលើសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជា។ ច្បាប់នានាជាច្រើនដែលផ្ដល់អំណាចដល់រដ្ឋាភិបាលដ៏ទូលំទូលាយនិងគ្មានមូលដ្ឋានគតិយុត្តិនោះ ជារឿយៗត្រូវបានអនុវត្តពុំត្រឹមត្រូវដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស និងមានគោលដៅបង្ក្រាបលើសេរីភាពបញ្ចេញមតិ។ ប្រសិនបើសេចក្ដីព្រាងច្បាប់នេះត្រូវបានអនុម័ត សេចក្ដីព្រាងច្បាប់នេះនឹងកាត់បន្ថយសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋនៅកម្ពុជាថែមទៀតដែលធ្វើឱ្យប៉ះពាល់ដល់ប្រទេសជាតិទាំងមូល។ អាស្រ័យហេតុដូច្នេះហើយ យើងខ្ញុំសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាទម្លាក់ចោលទាំងស្រុងនូវសេចក្ដីព្រាង*ច្បាប់ស្ដីពីសណ្ដាប់ធ្នាប់សាធារណៈនេះ* និងសូមឱ្យគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ៕

**---ចប់---**

អង្គការសង្គមស៊ីវិល សហជីព និងសហគមន៍ដែលគាំទ្រសេចក្ដីថ្លែងការណ៍នេះ មានរាយនាមដូចខាងក្រោម៖

១ អង្គការអោកសិនអេដ កម្ពុជា

២ វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ

៣ ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

៤ អង្គការលើកលែងទោសអន្តរជាតិ
៥ អង្គការមាត្រា១៩
៦ អង្គការសមាជិកអាស៊ានសម្រាប់សិទ្ធិមនុស្ស
៧ អង្គការវេទិកាអាស៊ីសម្រាប់សិទ្ធិមនុស្សនិងអភិវឌ្ឍន
៨ អង្គការបន្ទាយស្រី
៩ សហគមន៍បឹងទន្លេម្រេច
១០ សហគមន៍បឹងត្របែក
១១ សហគមន៍បុរីកីឡា
១២ សហគមន៍ប៊ូស្រា ខេត្តមណ្ឌលគិរី
១៣ អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
១៤ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)
១៥ អង្គការជនជាតិដើមភាគតិចកម្ពុជា
១៦ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
១៧ សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១៨ អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
១៩ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា
២០ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
២១ បណ្តាញយុវជនកម្ពុជា
២២ អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា(ស.ស.ក)
២៣ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ
២៤ សម្ព័ន្ធដើម្បីសុចរិតភាពនិងគណនេយ្យភាពសង្គម (CISA)
២៥ សម្ព័ន្ធសហគមន៍កសិករកម្ពុជា
២៦ បណ្តាញកសាងសន្តិភាពសហគមន៍ (CPN)
២៧ អង្គការសមធម៌កម្ពុជា (EC)
២៨ សហគមន៍អតីតបណ្តាញស្ត្រីបឹងកក់
២៩ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
៣០ អង្គការឃ្លាំមើលសិទ្ធិមនុស្ស
៣១ សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
៣២ សមាគមឥន្ទ្រទេវី (IDA)
៣៣ គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ)
៣៤ អង្គការសហព័ន្ធអន្តរជាតិសម្រាប់សិទ្ធិមនុស្ស (FIDH)
៣៥ អង្គការអាយហ្វិក (IFEX)
៣៦ សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA)

៣៧ ខ្មែរថាវរៈ
៣៨ សមាគមយុវជនខ្មែរ (KYA)
៣៩ ក្លាហាន
៤០ សហគមន៍កូនគ្រៀល ខេត្តឧត្តរមានជ័យ
៤១ សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើល
៤២ សហគមន៍ដីធ្លីភូមិភ្នំក្រិញ ខេត្តប៉ៃលិន
៤៣ សហគមន៍ដីធ្លីឡពាង ខេត្តកំពង់ឆ្នាំង
៤៤ អង្គការការពារសិទ្ធិជនជាតិភាគតិច (MIRO)
៤៥ មាតាធម្មជាតិកម្ពុជា (MN)
៤៦ សហគមន៍ការពារធនធានធម្មជាតិស្រុកក្រគរ ខេត្តពោធិសាត់
៤៧ គណៈកម្មាធិការអព្យាក្រិត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NECFEC)
៤៨ Not 1 More (N1M)
៤៩ សហគមន៍ភ្នំបាត
៥០ សហគមន៍ភ្នំក្រោម ខេត្តសៀមរាប
៥១ សហគមន៍ភូមិ ២៣
៥២ អង្គការពន្លកខ្មែរ (PKH)
៥៣ សហគមន៍ដីធ្លី ភូមិព្រែកជីក ឃុំជីខក្រោម ខេត្តកោះកុង
៥៤ សហគមន៍ព្រៃពាយ ខេត្តកំពត
៥៥ សហគមន៍ផ្លូវរថភ្លើង ទួលសង្កែ A
៥៦ សមាគមជាងត្នោត
៥៧ សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ
៥៨ សហគមន៍តានី ១៩៧ ឃុំជីខលើ ខេត្តកោះកុង
៥៩ គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងគ្រប់រូបភាពលើស្ត្រី
៦០ សហគមន៍ថ្មដាខេត្តពោធិសាត់
៦១ អង្គការតម្លាភាពកម្ពុជា (TIC)
៦២ សហគមន៍ត្រពាំងសង្កែ ខេត្តកំពត
៦៣ អង្គការនារីដើម្បីសន្តិភាព (WPM)
៦៤ អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT)
៦៥ ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)